# ផលិតកម្មពូជស្រូវស្រាលប្រជែញទឹក ឬស្រូវប្រាំង

## I. សេចក្តីផ្តើម

ស្រូវជាដំណាំស្បៀងមួយសំខាន់សម្រាប់ប្រជាជនកម្ពុជា ដែលចូលរួមចំណែកក្នុងផលិតផលក្នុងស្រុកនៃផលិតផលដំណាំប្រមាណ ៤៥% ។ ចាប់ពីឆ្នាំ ១៩៩៦ មកកម្ពុជាមានសល់ស្រូវសម្រាប់នាំចេញ ជាក់ស្តែងផ្ទៃដីដាំស្រូវបានកើនឡើងពី ២.៣៧ លានហិកតា ដោយទិន្នផលស្រូវ ២.១ តោន/ហិកតា នៅក្នុងឆ្នាំ ២០០៤។ បានកើនឡើងដល់ ២.៦១ លានហិកតា ដោយទទួលបានទិនផលស្រូវ ២.៧៤ តោន/ហិកតា នៅក្នុងឆ្នាំ ២០០៨ ។ ក្នុងឆ្នាំ ២០០៨ កន្លងទៅនេះយើងសម្រេចបានផលស្រូវសរុបប្រមាណជាង ៧.១៧៥ លានតោន ដោយយើងមានសល់ស្បៀងកម្រិតជាតិ ៣.១៦៤ លានតោនស្រូវ ស្មើនឹង ២.០២ លានតោនអង្ករ (ក្រសួងកសិកម្ម ខែមេសា ឆ្នាំ២០០៩) ដំណាំស្រូវនៅកម្ពុជាចែកចេញជា ៤ ប្រព័ន្ធក្សេត្របរិស្ថានគឺទី ១ ស្រូវស្រែទំនាបពឹងដោយរបបទឹកភ្លៀងដែលផ្ទៃដីប្រមាណ ២.១ លានហិកតា ទី២ ស្រូវឡើងទឹកមានផ្ទៃដីប្រមាណ ៩៥.១០០ ហិកតា ទី៣ ស្រូវចំការមានផ្ទៃដី ៥២.២៩០ ហិកតា និងទី ៤ ស្រូវប្រាំងប្រមាណ ៣៣៤.៧៩០ ហិកតា។ នៅកម្ពុជាផ្ទៃដីស្រែទំនាបពឹងដោយទឹកភ្លៀងមានប្រមាណ ២.១ លានហិកតា ឬ ៩៣% នៃផ្ទៃដីដាំដុះនៅរដូវវស្សាមានប្រមាណ ២.៥០ លានហិកតា (ស្ថិតិកសិកម្ម ក្រសួងកសិកម្ម ខែ មេសា ឆ្នាំ២០០៩) ដែលបានដាំដុះ គ្រប់ខេត្តទាំងអស់នៅកម្ពុជា។ ស្រូវប្រភេទនេះត្រូវបានដាំដុះនៅលើប្រភេទដីផ្សេងៗគ្នាហើយដោយផ្អែកទៅតាមរយៈពេលនៃការលូតលាស់ ឬនៅពេលចេញផ្កា ដោយចែកប្រភេទពូជស្រូវជាបីប្រភេទសំខាន់ៗ គឺ ប្រភេទពូជស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់ ។ នៅក្នុងឆ្នាំ ២០០៨ ផ្ទៃដីដាំដុះស្រូវមានប្រមាណ ៥២៧.០០០ ហិកតា ស្រូវកណ្តាលមាន ១.០៣ លានហិកតា និងស្រូវធ្ងន់មាន ៥៤៦.៤៦៤ ហិកតា។

ក្នុងបរិការណ៍នេះ ក្រោមការជួយឧបត្ថម្ភគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី ADB និងមានកិច្ចសហការពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា CARDI នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

បានរៀបចំបោះពុម្ពកូនសៀវភៅស្តីពីផលិតកម្មស្រូវស្រាលប្រដេញទឹក និងស្រូវប្រាំង ដែលមានពូជស្រូវសែនពិដោរ អ៊ីរ៉ៃអ៊ែកេសរ អ៊ីរ៉ៃអ ៦៦ អ៊ីរ៉ៃអ ៧២ គ្រូ របាត់ជលសារ រំពេរ និងពូជស្រូវបារាយណ៍ ក្នុងគោលបំណងលើកស្ទួយ និងជួយដល់ប្រជាកសិករដែលប្រកបការងារដាំដុះដំណាំស្រូវជាមូលដ្ឋានឱ្យមានជីវភាពធូរធារតាមរយៈការបញ្ជ្រាបបច្ចេកវិទ្យាកសិកម្មតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ។









ពូជស្រូវសែនពិដោរ អ៊ីអ៊ែរកេសរ អ៊ីអ៊ែរ ៦៦ អ៊ីអ៊ែរ ៧២ គ្រូ រហាត់ជល់សារ រំពេរ និងពូជស្រូវបាវាយណ៍ ជាពូជស្រូវស្រាល (អាយុកាលខ្លី) ក្រអូប និងមិនប្រកាន់រដូវដែលបានធ្វើការរំដោះ និងផ្សព្វផ្សាយដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នាខែមេសា ឆ្នាំ ២០០២ ។ បច្ចុប្បន្ន ពូជស្រូវទាំងនេះ បាននិងកំពុងរីកសាយភាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពូជស្រូវនេះ ផ្តល់



ទិន្នផលខ្ពស់ មានក្លិនក្រអូប គុណភាពអង្ករល្អមានភាពថ្លាវែងរលូន និងបាយទន់ឆ្ងាញ់ពិសារទៀតផង។ ជាពិសេសទៅទៀត ជាពូជដែលមានប្រភេទអង្ករមានតំលៃខ្ពស់នៅលើទីផ្សារជាតិ និងអន្តរជាតិ។

## II. លក្ខណៈពិសេសៗរបស់ពូជស្រូវ អ៊ីអ៊ែរកេសរ អ៊ីអ៊ែរ ៦៦ អ៊ីអ៊ែរ ៧២គ្រូ រហាត់ ជលសារ រំពេរ និងពូជស្រូវបាវាយណ៍

ដោយសារពូជស្រូវទាំងនេះ ជាពូជមិនប្រកាន់រដូវ ដូចនេះ ពូជនេះអាចចេញផ្កាបានគ្រប់ពេលវេលា ដរាបណាល័ក្ខខ័ណ្ឌ ដាំដុះអំណោយផល។ អាស្រ័យហេតុផលខាងលើនេះទើបពូជស្រូវសែន អ៊ីអ៊ែរកេសរ អ៊ីអ៊ែរ ៦៦ អ៊ីអ៊ែរ ៧២គ្រូ រហាត់ ជលសាររំពេរ

និងពូជស្រូវបារាណ៍អាចដាំដុះនៅដើមរដូវវស្សា (ដំណាំទីមួយនៃរដូវ ឬស្រូវដើមរដូវ) ក្នុងរដូវវស្សា (ដំណាំទីពីរនៃរដូវ) ចុងរដូវវស្សា ស្រូវប្រដេញទឹក (ដំណាំចន្លោះរដូវវស្សានិងរដូវប្រាំង) និងលក្ខខ័ណ្ឌប្រាំងស្រោចស្រព។ ប្រភេទពូជស្រូវស្រាលនេះមានអាយុកាលចាប់ពីថ្ងៃសាប រហូតដល់ថ្ងៃប្រមូលផលពី ១១០ - ១២០ ថ្ងៃ។ កំពស់ដើមរបស់ពូជនេះប្រែប្រួលពី ៩៥ - ១១០ ស.ម និងចំនួនដើមបែកគឺចាប់ពី ៥ - ២០ ដើមក្នុង ១គុម្ព។ ចំនួនគ្រាប់ក្នុងមួយគួរមានចាប់ពី ១១០ - ១៧០ គ្រាប់ និងមានប្រវែងគួរ ២០ - ៣០ ស.ម។ រីឯទិន្នផលរបស់វាវិញ គឺអាចទទួលបានចាប់ពី ៣,៥ តោន ទៅ ៥,៥ តោនក្នុងផ្ទៃដី ១ ហិកតា។

## III. បច្ចេកទេសដាំដុះ

### ១. ការជ្រើសរើសពូជ

- ប្រើប្រាស់គ្រាប់ពូជដែលសុទ្ធល្អ និងមានអត្រាដំណុះខ្ពស់។
- កំរិតបរិមាណ គ្រាប់ពូជចាំបាច់ ៣០ - ៥០ គ .ក្រ ក្នុងមួយហិកតា សំរាប់ស្រូវស្ទូង និង ៨០ - ១២០ គ.ក្រ ក្នុង ១ ហិកតា សំរាប់ស្រូវពង្រួស។
- ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ឈើ ឬកន្លែងមានភ្លើងអគ្គិសនីដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។
- ផ្ទៃដីសំរាប់សាបគឺ ១ គ.ក្រ ផ្ទៃដី ១៥ - ២០ ម៉ែត្រការ៉េ។
- ជាការល្អគួរស្ទូងសំណាបដែលមានអាយុ ២០ - ២៥ ថ្ងៃ ហើយក្នុង ១ គុម្ព ក្នុងចន្លោះ ២០ ស.ម x ២០ ស.ម ។
- គួររៀបចំដីអោយបានល្អមុនស្ទូង។ ការភ្ជួររាស់ គួរតែធ្វើអោយបាន ២-៣ សារជាការល្អ ។ បើសិនស្រែយើងអាចបញ្ចេញទឹកបាន ពេលស្រូវបែកគុម្ពត្រូវបញ្ចេញទឹកអោយអស់ពីក្នុងស្រែក្នុងរយៈពេល ២-៤ ថ្ងៃ រួចទើប បញ្ចូលទឹកឡើងវិញ ដើម្បីធ្វើអោយស្រូវកាន់តែបែកគុម្ពល្អ




## ២. ការរៀបចំថ្នាលសំណាប និងគ្រប់គ្រងសំណាប

- ជ្រើសរើសដីធ្វើថ្នាលសំណាបឱ្យជិតប្រភពទឹក ហើយជាដីស្រែដែលរៀបស្មើល្អ និងមានជីជាតិបង្គួរ ទៅល្អ និងភ្ជួររាស់ឱ្យបានពីរទៅបីដង រួចគៀរដីឱ្យរាបស្មើ និងប្រើជីធម្មជាតិឱ្យបានច្រើន។
- ថ្នាលសំណាបអាចរៀបចំជាថ្នាលទឹក ឬជាថ្នាលគោក តាមស្ថានភាពជាក់ស្តែង (តែជាទូទៅកសិករនិយមថ្នាលទឹកដោយប្រើគ្រាប់ពូជសុទ្ធល្អ ដែលមានដំនុះគ្រាប់ពី ៩០% ទៅ ៩៥%)ហើយត្រូវត្រាំគ្រាប់ស្រូវ ២៤ ម៉ោង និងផ្អាប់ពី ២៤ ទៅ ៤៨ ម៉ោង ដើម្បីឱ្យគ្រាប់ស្រូវដុះពន្លកល្អ។ ថ្នាលសំណាបត្រូវលើកជារងតូចៗកំពស់ពី ១០ ទៅ ២០ ស.ម ទទឹងខ្នងរង ១ម៉ែត្រ និងបណ្តោយរង ១០ ម៉ែត្រ អាចសាបគ្រាប់ជាជួរ ឬ ព្រោះគ្រាប់ដោយប្រើពូជពី ១៥ ទៅ ២០ គ.ក្រ សំរាប់ស្ទូង ១ ហិកតា ឬ សាប ១ គ.ក្រ ក្នុង ១០ ម៉ែត្រការ៉េ ឬ មួយរង ព្រោះឱ្យស្តើង ដើម្បីឱ្យសំណាបថ្លោសល្អ។



- ត្រូវថែទាំថ្នាលសំណាបជាប្រចាំ រក្សាទឹក និងការពារសត្វល្អិតបំផ្លាញដូចជាពពួកមមាច ត្នោត មមុង (ទ្រីប) ដង្កូវបំពង់កាត់ស្លឹក និងដង្កូវហ្វូងជាដើម អោយសំណាបអាចត្រឹម ១៥-២០ ថ្ងៃអាចដកទៅស្ទូង តែត្រូវដកភ្លាមយកទៅស្ទូងភ្លាមក្នុងថ្ងៃតែមួយ។



## ៣. ការរៀបចំស្រែសន្ទូង និងការស្ទូង

ត្រូវរៀបចំដីស្រែឱ្យបាន ២ទៅ ៣ដង ដោយភ្ជួររាស់ដី ១ ដង ភ្ជួររាស់ ១ - ២ ដងនៅមុនពេល ស្ទូងនិងគៀររាស់ដីស្រែឱ្យរាបស្មើល្អ និងលើកភ្លឺ



ស្រែឱ្យបានធំ ខ្ពស់ និងជាប់ល្អ ងាយស្រួលក្នុងការគ្រប់គ្រងទឹក ។ ស្ទូង ១ ដើម ទៅ ៣ ដើម ក្នុង ១ គុម្ព ជាជួរ ឬ ធម្មតា(ជាមុំចង្ក្រាន) ដោយចន្លោះ ២៥ ស.ម x ២៥ ស.ម ឬ ស្ទូង ២០ គុម្ពក្នុង ១ ម៉ែត្រការ៉េ ស្ទូងជាជួរជាការអនុវត្តល្អប្រសើរមួយ គឺងាយស្រួលក្នុងការថែទាំសន្ទូង។ ត្រូវធ្វើការជួសសន្ទូងចំពោះគុម្ពណាដែលបាត់ក្រោយពីស្ទូងពី ៥ ទៅ ៧ ថ្ងៃ ។





ពូជស្រូវ អ៊ីអ៊ែ ៦៦ និងពូជស្រូវសែនពិដោរ

## ៤. ការប្រើប្រាស់ជី

- ប្រើប្រាស់ឱ្យបាន ៣ ដង នៅក្នុងរយៈពេលលូតលាស់របស់ដំណាំស្រូវគឺ ប្រើជីទ្រាប់បាត មុនពេលស្ទូង ១ ដង និងប្រើជីបំប៉ន ២ ដង គឺ នៅក្រោយពេលស្ទូង ៣០ ថ្ងៃ បាចម្តង និងនៅពេលស្រូវកំណាកំណើតកួរ ឬស្រូវមូរដើម ១ ដង

- ប្រើជីទ្រាប់បាតនៅមុនពេលស្ទូង ១ ថ្ងៃ ឬនៅពេលជាមួយស្ទូង ដោយភ្ជួរ និងរាស់ជីកប់ទៅក្នុងដី។ ប្រើជីទ្រាប់បាតនៅលើដីល្បាយខ្សាច់គឺ ជីកំប៉ុស្ត ពី



**ការបាចជីបំប៉នលើពូជស្រូវសែនពិដោរ និងពូជស្រូវអ៊ីអ៊ែរ កេសរ**

៥ ទៅ ១០ តោន (តាមលទ្ធភាពរកបាន) និងជី ដេ. អា. ប៉េ ចំនួន ៥០ គ.ក្រ និង ជីប៉ូតាស្យូមក្លរួ ៥០ គ.ក្រ ក្នុង ១ ហិកតា។

- ប្រើជីបំប៉នលើកទី ១ នៅក្រោយពេលស្ទូង ៣០ ថ្ងៃ នៅក្នុងដំណាក់កាលបែកគុម្ព ដើម្បីជួយឱ្យស្រូវបែកដើមច្រើនដោយប្រើជីអ៊ុយរ៉េ ២២ គ.ក្រ ក្នុង ១ ហិកតា។
- បាចលើកទី ២ ក្នុងដំណាក់កាលស្រូវកកើតកួរ ឬមូរដើម ដើម្បីឱ្យស្រូវមានកួរវែងមានគ្រាប់ច្រើននិងស្រូវដាក់គ្រាប់ពេញល្អ ដោយប្រើជីអ៊ុយរ៉េ ២២ គ.ក្រ ទៀតក្នុង ១ហិកតា

## IV. ការថែទាំ

- ត្រូវចុះពិនិត្យស្រែ និងតាមដានការលូតលាស់របស់ដំណាំស្រូវជារបចាំក្រោយពេលស្ទូងរួច។ ត្រូវធ្វើការជួសសន្ទូងនូវគុម្ពណាដែលបាត់ ក្រោយពេលស្ទូងពី ៥ ទៅ ៧ ថ្ងៃ និងថែទាំទឹក បោចស្មៅ និងត្រួតពិនិត្យប្រជាករកត្តាចង្រៃផ្សេងៗដូចជា សត្វល្អិត ជំងឺ ស្មៅចង្រៃ និងសត្វល្អិតមានប្រយោជន៍ នៅក្នុងស្រែជាប្រចាំ។ ជាពិសេសត្រូវតាមដានវត្តមានសត្វល្អិតបំផ្លាញសំខាន់ ដើម្បីមានវិធានការការពារ និងកំចាត់ តាមវគ្គលូតលាស់របស់ដំណាំស្រូវដូចជាក្នុងដំណាក់កាលលូតលាស់



(សន្ទូង) មានមមាចត្នោត ដង្កូវបំពង់កាត់ស្លឹក ដង្កូវស៊ីរូងដើម ដង្កូវហ្វូង។ល។ ដំណាក់កាលដាក់ទឹកដោះមានដង្កូវមូរស្លឹក ស្រឹង កណ្ដុរ និងសត្វចាបជាដើម។

- ត្រូវរក្សាទឹកឱ្យមានក្នុងស្រែជាប្រចាំតាមកំរិតកម្ពស់ ៥ ទៅ ១០ ស.មរហូតដល់ស្រូវទុំស្លាប សេក ជាពិសេស នៅដំណាក់កាលស្រូវកកើតគួរ ឬមូរដើម រឹងភ្លឺស្រែក៏ត្រូវមានសភាព ជាប់និងជិតល្អ។

- ត្រូវធ្វើការជួសសន្ទូងនូវគុម្ពណាដែលបាត់ក្រោយពេលស្ទូង។







## V. ការប្រមូលផល

- ត្រូវធ្វើការច្រូតកាត់នៅរវាង ៣០ - ៣៥ ថ្ងៃបន្ទាប់ពីស្រូវហាលផ្កាស្រុះ ឬ ពេលដែល ប្រមាណ ៨៥% នៃគ្រាប់ស្រូវទុំ។
- ត្រូវហាល ២ - ៣ ថ្ងៃ ដើម្បីបន្ថយសំណើមនៅក្នុងគ្រាប់អោយនៅ ១៤ ភាគរយនឹងទុក ជាការល្អ។ សូមយកគ្រាប់ស្រូវមកខាំ ដើម្បីកំណត់បើគ្រាប់ស្រូវនោះបាក់គឺ មានន័យថា គ្រាប់ស្រូវស្ងួតល្អ។
- ពូជត្រូវច្រកទុកនៅក្នុងបាវក្រចៅ ជាការប្រសើរ
- ការទុកដាក់ពូជត្រូវមានកំណល់ មិនត្រូវដាក់បាវពូជផ្ទាល់និងឥដ្ឋទេ។
- សរសេរឈ្មោះពូជ និង ថ្ងៃខែច្រូតកាត់ដាក់លើបាវ។

